# តើ...
# ប្រជាជននិយាយអំពី?

“ខ្ញុំគិតថា អ្នកដែលមានស្ថានភាពដូចខ្ញុំដែលធ្លាប់ទទួលរងការឈឺចាប់ពីបញ្ហាការគ្រប់គ្រងសុខភាព នឹងទទួលបានគុណប្រយោជន៍ពីកម្មវិធីនេះមិនខាន ពីព្រោះវាជួយប្រជាជនក្នុងការវិលត្រលប់ទៅរកការរស់នៅធម្មតា របស់ពួកគេវិញ និង ជួយតំរង់គោលដៅ និង អោយក្តីសង្ឃឹម។”

“គិលានុបដ្ឋ និង អ្នកមើលថែផ្ទាល់ខ្លួនរបស់ខ្ញុំ ជាញឹកញយធ្លាប់ទៅការណាត់ជួបពេទ្យជាមួយរូបខ្ញុំ ដែលជាសកម្មភាពមួយជួយអោងខ្ញុំយល់ដឹងកាន់តែច្បាស់ រាល់សំនួរពីគ្រូពេទ្យ។ ខ្ញុំជឿថា សកម្មភាពគិលានុបដ្ឋរបស់ខ្ញុំ កន្លងមកបានជួយលើរូបខ្ញុំអោយកាន់តែប្រសើរឡើង ពីទិដ្ឋភាពខាងក្រៅរបស់ខ្ញុំ និង សុខមលភាព។ ខ្ញុំបោះបង់ចោលការជក់បារី និង មិនដែលកាន់បារីតាំងពីខែវិច្ឆិកា។”



ការគ្រប់គ្រងមើលថែយូរអង្វែង (**Chronic Care**) ផ្តល់ជូនសេវាកម្មដូចខាងក្រោម:

- ការធ្វើតេស្តប៉ាន់ប្រមាណសុខភាព។
- គំរោងសកម្មភាពសុខភាពឯកត្តជន។
- ផ្តល់ជូនការសម្របសម្រួលការថែទាំសុខភាព និង សេវាផ្សេងទៀត។
- ការអប់រំ និង ការបង្ហាត់បង្ហាញ។
- ជួយសំរួលការមើលថែរបស់អ្នកបើសិនជាអ្នកធ្លាប់ព្យាបាលនៅមន្ទីរពេទ្យ។

## សំរាប់ព័ណមានបន្ថែម

Aging and Disability
Services Administration

1-800-422-3263

ភ្នាក់ងារតំបន់ និង ជរាភាព

Washington State
Department of Social
& Health Services

ADSA Aging & Disability
Services Administration

DSHS 22-1476 CA (2/12)

វាជាសុខភាពរបស់អ្នក

# ការទទួលខុសត្រូវ

រៀនពីពិធីថ្មី ដើម្បីគ្រប់គ្រងសុខភាពរបស់អ្នកនៅគេហដ្ឋានជាមួយនឹងការគ្រប់គ្រងមើលថែយូរអង្វែង



តើ...

# ការគ្រប់គ្រងមើលថែយូរអង្វែង (Chronic Care Management) ជាអ្វី?

- គំរោងសកម្មភាពអំពីសុខភាពមួយ ដែលផ្តោតទៅលើគោលដៅសុខភាពរបស់អ្នក និង ជំនួយដែលអ្នកប្រហែលជាត្រូវការដើម្បីឈានទៅរកគោលដៅនោះ។
- ពង្រឹងសេចក្តីទុកចិត្តជាមួយអ្នកធ្វើការទាក់ទងនឹងសុខភាពរបស់អ្នកដូចជា: គ្រូពេទ្យ, គិលានុបដ្ឋា និង អ្នកធ្វើសសៃ។
- ជួយក្នុងការណាត់ជួបពេទ្យ។
- បន្ថែមជំនឿទុកចិត្តអ្នកក្នុងភារៈកិច្ចមើលថែសុខភាពរបស់អ្នក។
- គាំទ្រអ្នកក្នុងការជួររបបរស់នៅរបស់អ្នក ដែលប្រកបទៅដោយផាសុខភាព។
- ការអប់រំស្តីអំពី ការទប់ស្កាត់បញ្ហាសុខភាពរបស់អ្នក នៅពេលខាងមុខ។



## តើសេវាទាំងនោះសំរាប់ខ្ញុំឬ?

- អ្នកចាត់ការគិលានុបដ្ឋរបស់អ្នក នឹងធ្វើការជាមួយអ្នកគ្រប់គ្រងរឿងរ៉ាវរបស់អ្នក ហើយនិង គ្រូពេទ្យរបស់អ្នកដើម្បីផ្គត់ផ្គង់អ្នកក្នុងការងារក្រុមរបស់អ្នក។
- សេវាកម្មពីអ្នកចាត់ការគិលានុបដ្ឋរបស់អ្នក អាចជួយកាត់បន្ថយការពិគ្រោះនៅមន្ទីរពេទ្យ និង បន្ទប់សង្គ្រោះបន្ទាន់ ហើយនិង គាំទ្រការរីកចំរើនសុខភាពរបស់អ្នកដោយការមើលថែខ្លួនឯង។

## តើសេវាទាំងនោះអស់ថ្លៃប៉ុន្មាន?

- សេវាកម្មធានារ៉ាប់រងសុខភាព(Medicaid) នឹងចេញអោយសំរាប់សេវាកម្មនេះ។
- អ្នកនឹងមិនចំណាយប្រាក់លើសេវានេះទេ។
- អ្នកនឹងបានសេវាកម្មធានារ៉ាប់រងរបស់អ្នកទាំងអស់ដូចពេលមុនដែរ។

## តើខ្ញុំនឹងរៀនពីអ្វី?

អ្នកចាត់ការគិលានុបដ្ឋរបស់អ្នក អាចជួយអ្នករៀនបន្ថែមអំពី:

- គ្រប់គ្រងការប្រើប្រាស់ថ្នាំរបស់អ្នក។
- គ្រប់គ្រងស្ថានភាពសុខភាពរបស់អ្នក។
- ជួយអ្នកដើម្បីទទួលបានសេវាសុខភាពក្នុងសហគមនរបស់អ្នក

## តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

- ធ្វើការជាមួយ គិលានុបដ្ឋកំឡុងពេលត្រួតពិនិត្យ និង តាមទូរស័ព្ទ។
- ធ្វើគំរោងជាមួយ គិលានុបដ្ឋអំពី ការចង់ធ្វើមួយរបស់អ្នកដើម្បីភាពប្រសើរឡើងនៃសុខភាពរបស់អ្នក។

## តើខ្ញុំនឹងធ្វើការជាមួយនរណាខ្លះ?

- គិលានុបដ្ឋជំនាញម្នាក់ ដែលជាចាត់ទុកជាគ្រូបង្វឹកបង្ហាត់ពីការមើលថែសុខភាពរបស់អ្នក។
- ភ្នាក់ងារតំបន់របស់អ្នក និង អ្នកចាត់ការរឿងក្តីរបស់អ្នក
- អ្នកមើលថែអ្នក និង អ្នកដទៃទៀតដែលជាអ្នកធ្វើការជាមួយអ្នក
- បុគ្គលដែលអ្នកគិតថាជាមនុស្សសំខាន់សំរាប់អ្នកមានដូចជា អ្នកណែនាំសុខភាព និង អ្នកព្យាបាលរោគ

## តើអ្វីខ្លះដែលខ្ញុំអាចដឹងថាខ្ញុំមានលក្ខណ:គ្រប់គ្រាន់?

- ទទួលបានសេវាកម្មធានារ៉ាប់រងសុខភាព(Medicaid) សំរាប់ការមើលថែ។
- មានគ្រោះថ្នាក់ទាក់ទងនឹងបញ្ហាសុខភាព។
- ទទួលបានសេវាកម្មមើលថែផ្ទាល់ខ្លួននៅក្នុងផ្ទះរបស់អ្នក។